ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៣ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ទីស្ដីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

១៦-១-១៩៩៥ - អនុក្រឹត្យលេខ ០៧ អនក្រ ស្ដីពីការបង្កើតគណៈកម្មការទំនាក់ទំនងការងារ
ជាមួយកងយោធពលភូមិន្ទថៃ ៧០

១៦-១-១៩៩៥ -អនុក្រឹត្យលេខ ០៨ អនក្រ ស្ដីពីការបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ៧២

២៣-១-១៩៩៥ -អនុក្រឹត្យលេខ ០៩ អនក្រ ស្ដីពីការបែងចែកឥណទានតាមជំពូកនៃ
ច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ .... ៧៣

១៦-១-១៩៩៥ -អនុក្រឹត្យលេខ ០៤ អនក្រ ស្ដីពីការតែងតាំងមន្ត្រី- រាជការ ៨៦

-អនុក្រឹត្យលេខ ០៥ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨៧

២.សេចក្ដីសំរេច

១៦-១-១៩៩៥ -សេចក្ដីសំរេចលេខ ០៩ សសរ ស្ដីពីការកំណត់សិទ្ធិ និង ភារកិច្ចរបស់បណ្ដាអង្គភាព
ដែល បំពេញកិច្ចការប្រចាំនៅអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ៨៨

២១-១-១៩៩៥ -សេចក្ដីសំរេចលេខ ១០ សសរ ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន ៩១

II - ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សេចក្ដីសំរេច

១៧-១-១៩៩៥ -សេចក្ដីសំរេចលេខ ០០១ សហវ-ខ សសរ ស្ដីពីការបង្កើតអនុគណៈកម្មាធិការ
រៀបចំអនុវត្តគោលការណ៍ ស្ដីពីការគ្រប់គ្រងមន្ត្រីរាជការគយ និង រដ្ឋាករ

តាមស្មារតីសារាចររបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០១ សរ.សហវ_តរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ .... ៩២

២. លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១៦-១-១៩៩៥ - ប្រកាសលេខ ០១២ ពណ.បល.ប្រក ៩៤

៣. លិខិតការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៣-១-១៩៩៥ - ប្រកាសលេខ ៤៦ ផក.ប្រក អនុញ្ញាតអោយលោក ឈន សាវ៉ាណេ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រិតអង្ករឈ្មោះ ហៅ " មានហួរ " ៩៦

២៣-១-១៩៩៥ - ប្រកាសលេខ ៥៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ជា ហ៊ាង ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ ៩៦

២៣-១-១៩៩៥ - ប្រកាសលេខ ៥៥ ផក.ប្រក អនុញ្ញាតអោយលោក ហុង វេងស៊ា ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មផលិតទឹកកកដើម ៩៧

៤. លិខិតការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

១៨-១-១៩៩៥ - ប្រកាសលេខ ០១៦ ប្រកសក.ចត ស្តីពីការតែងតាំងគ្រូបង្រៀន ប្រចាំសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប ឆ្នាំសិក្សា ១៩៩៤-១៩៩៥ .... ៩៨

២០-១-១៩៩៥ - ប្រកាសលេខ ០២០ ប្រក កសក.ចត ស្តីពីការបង្កើតគណៈកម្មការអធិការកិច្ច លើចំនួនក្របខ័ណ្ឌរបស់ក្រសួង ១០២

២១-១-១៩៩៥ - ប្រកាសលេខ ០២២ កសក ស្តីពីការអនុញ្ញាតអោយលោក ឡេា សុភ័ក្ត បើក កសិដ្ឋានចិញ្ចឹមពូជមាន់សាច់ ១០៣

៥- ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៧-១-១៩៩៥ - ប្រកាសលេខ ០១៣/៩៥ ពប.ប្រក ១០៥

៦- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

១៨-១-១៩៩៥ - ប្រកាសលេខ ០៤៦ ប្រក មល.បល ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ១០៦

២០-១-១៩៩៥ - ប្រកាសលេខ ០៥០ ប្រក.មល.បល ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ១០៧

៧- ទីស្ដីការក្រសួងធម្មការ និង សាសនា

ប្រកាស

២០-១-១៩៩៥ - ប្រកាសលេខ ១៤/៩៥ កធស ស្ដីពីការតែងតាំងមន្ត្រីរាជការ ១០៨

I- ផ្នែកិច្ចការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៧ អនក្រ
ស្ដីពីការបង្កើតគណៈកម្មការទំនាក់ទំនង
ការងារជាមួយកងយោធពលភូមិន្ទ ថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រឹត្យ ចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតអគ្គសេនាធិការកងទ័ពជាតិកម្ពុជា
- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយ កងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខធានាសុវត្ថិភាពនៅតាមព្រំ ដែនកម្ពុជា-ថៃ
- តាមសំណើរបស់អគ្គសេនាធិការ

សំរេច

មាត្រា ១ : - បង្កើតគណៈកម្មការកណ្ដាលមួយ ស្ថិតក្រោមការដឹកនាំបញ្ជាផ្ទាល់ របស់សហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ដើម្បីទំនាក់ទំនងការងារ ជាមួយកងយោធពលភូមិន្ទថៃ ដែលរួមមានសមាសភាពដូចខាងក្រោម ៖

០១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ប៉ុល សារឿន** នាយរងអគ្គសេនាធិការ ជាប្រធាន

០២-ឯកឧត្តម **អ៊ុង ស៊ាង** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

០៣_ឯកឧត្តម ឧត្តមសេនីយ៍ឯក **គ្រុច យឿម** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

០៤_លោកឧត្តមសេនីយ៍ **ចំរើន ជាតិ** មេបញ្ជាការការពារព្រំដែន ជាសមាជិក

០៥_លោកឧត្តមសេនីយ៍ **ជុម ហាក់** នាយរងការិយាល័យទី ២ ជាសមាជិក

០៦_លោកឧត្តមសេនីយ៍ **សិទ្ធ ហ៊ិន** នាយរងក្រុមស្រាវជ្រាវ ជាសមាជិក

០៧_លោកឧត្តមសេនីយ៍ **ឡាយ ម៉ិនសុខ** នាយកនាយកដ្ឋានទាក់ទងអន្តរជាតិ ជាសមាជិក

០៨_លោកឧត្តមសេនីយ៍ **ហេង ហុង** មេបញ្ជាការរងយោធភូមិភាគទី ៣ ជាសមាជិក

០៩_លោកឧត្តមសេនីយ៍ **ជួង សុខុន** មេបញ្ជាការរងយោធភូមិភាគទី ៥ ជាសមាជិក

១០_លោកឧត្តមសេនីយ **នួន ចណ្ណា** មេបញ្ជាការរងយោធភូមិភាគទី ៤ ជាសមាជិក

១១_លោកឧត្តមសេនីយ **ឆៀ ចិញ** មេបញ្ជាការរងកងនាវាចរខេមរភូមិន្ទ ជាសមាជិក

មាត្រា ២ : _ចាត់តាំងគណៈអចិន្ត្រៃយ៍ សំរាប់ជំនួយដល់គណៈកម្មការកណ្តាល សំរាប់ដោះស្រាយការងារប្រចាំថ្ងៃដែលរួមមាន សមាសភាពដូចខាងក្រោម ÷

០១_ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** ជាប្រធាន

០២_លោក ឧត្តមសេនីយ៍ **ចំរើន ជាតិ** សមាជិកអចិន្ត្រៃយ៍

០៣_លោកឧត្តមសេនីយ៍ **ជុម ហាក់** សមាជិកអចិន្ត្រៃយ៍

០៤_លោកឧត្តមសេនីយ៍ **សិទ្ធ ហ៊ិន** សមាជិកអចិន្ត្រៃយ៍

០៥_លោកវរៈសេនីយ៍ **សេង ម៉ាន់ធី** ជាសមាជិក

មាត្រា ៣ : _ដើម្បីជំនួយដល់គណៈកម្មការកណ្តាលនេះ ក្នុងការសហការដោះស្រាយការងារបានល្អនៅតាមភូមិសាស្ត្រនិមួយៗ ចាំបាច់ត្រូវរៀបចំអនុគណៈកម្មការ និងក្រុមការងារមួយចំនួនប្រចាំការតាមបណ្តាទិស នៃយោធភូមិភាគនិមួយៗ ។ ចំពោះសមាសភាពនិងភារកិច្ចរបស់អនុគណៈកម្មការ និងក្រុមការងារនិមួយៗ អាស្រ័យលើអគ្គសេនាធិការរៀបចំ និងកំណត់ជាក់ស្តែង ។

មាត្រា ៤ : _គណៈកម្មការកណ្តាលនេះ មានភារកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចកងយោធពលខេមរភូមិន្ទថៃ ដើម្បីពិគ្រោះគ្នាដោះស្រាយអោយបានល្អនូវរាល់បាតុភាព ឧប្បត្តិហេតុផ្សេងៗដែលកើតឡើងនៅតាមព្រំដែនកម្ពុជា_ថៃ បង្កើតឡើងនូវបរិយាកាស សន្តិសុខ សុវត្ថិភាព នៅតាមបណ្តាព្រំដែននៃប្រទេសទាំងពីរ ។

មាត្រា ៥ : _ទីកន្លែងធ្វើការងាររបស់គណៈអចិន្ត្រៃយ៍ នៃគណៈកម្មការកណ្តាលកំណត់យកទីបញ្ជាការដ្ឋានការពារព្រំដែនអគ្គសេនាធិការ ។

មាត្រា ៦ : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

មាត្រា ៧ : _ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ នាយអគ្គសេនាធិការ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ និង សាមីជនដែលមានឈ្មោះក្នុងគណៈកម្មការត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ។

មាត្រា ៨ : _អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៨ អនក្រ
ស្តីពីការបង្កើត បញ្ជាការដ្ឋាន កងរាជអាវុធហត្ថ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជា ធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២នៃរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា ។

_បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ

_យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថប្រចាំ ខេត្ត ក្រចេះ,ខេត្ត កំពង់ធំ,ខេត្ត តាកែវ,ខេត្ត ពោធិសាត់,ខេត្ត កំពត,ខេត្ត កោះកុង និង ក្រុងកែបបូកគោ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៩ អនក្រ
ស្តីពីការបែងចែកឥណទាន
តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : ឥណទានសំរាប់ចំណាយជាប្រចាំ និង ជាមូលធនរបស់រដ្ឋ ដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ត្រូវបានបែងចែកតាមជំពូក ដោយអនុលោមតាមតារាងដែលភ្ជាប់ នឹង អនុក្រឹត្យនេះ ។

មាត្រា ២ : ការបែងចែកឥណទាននៃជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ តទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥

តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការរាយមុខ	ចំនួន ឥណទាន
	១— ព្រះបរមរាជវាំង	
១០	បៀវត្ស និង ប្រាក់បំណាច់	5 160
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2 130
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	2 310
	សរុបរួម ១	9 600
	២— សភាជាតិ	
១០	បៀវត្ស និង ប្រាក់បំណាច់	6 410
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2 430
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	140
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	100
	សរុបរួម ២	9 080
	៣— ទីស្តីការគណៈរដ្ឋមន្ត្រី	
	ផ្នែក ១– គណៈរដ្ឋមន្ត្រី	
១០	បៀវត្ស និង ប្រាក់បំណាច់	1 075
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	12 115
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	4 155
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	910
	សរុបផ្នែក ១	18 255
	ផ្នែក ៤– ទំនាក់ទំនងជាមួយសភា	
១០	បៀវត្ស និង ប្រាក់បំណាច់	100
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	500
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុបផ្នែក ៤	610
	ផ្នែក ៦– មុខងារសាធារណៈ	
១០	បៀវត្ស និង ប្រាក់បំណាច់	70
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	265
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
	សរុបផ្នែក ៦	340

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការរាយមុខ	ចំនួន ឥណទាន
	ផ្នែក ៧– អាកាសចរណ៍ស៊ីវិល	
១០	បៀវត្ស និង ប្រាក់បំណាច់	430
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	2 400
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុប ផ្នែក ៧	2 840
	សរុបរួម ៣	22 045
	៤– ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	
១០	បៀវត្ស និង ប្រាក់បំណាច់	4 650
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	17055
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	580
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	665
	សរុបរួម ៤	22 950
	៥– ក្រសួងការពារជាតិ	
១០	បៀវត្ស និង ប្រាក់បំណាច់	153 300
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	62 700
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	4 000
	សរុបរួម ៥	220 000
	៦– ក្រសួងមហាផ្ទៃ	
	ផ្នែក ១ សន្តិសុខសាធារណៈ	
១០	បៀវត្ស និង ប្រាក់បំណាច់	34 855
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	48 140
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	1 055
	សរុបផ្នែក ១	84 050
	ផ្នែក ២– រដ្ឋបាលទូទៅ	
១០	បៀវត្ស និង ប្រាក់បំណាច់	185
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	3 200
១២	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	3 000
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	165
៥១	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	19 200
	សរុបផ្នែក ២	25 750

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយចរន្តប្រចាំ និង ចាយមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	ផ្នែក ៤-ខេត្តក្រុង	
១០	បៀវត្ស និង ប្រាក់បំណាច់	4 530
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	3 070
១២	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	8 135
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	215
	សរុបផ្នែក ៤	15 950
	សរុបរួម ៦	125 750
	៧— ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	
	ផ្នែក ១ ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	2 400
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	3 455
១២	ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល	2 935
២០	ការប្រាក់នៃប្រាក់ខ្ចីបុលរយៈពេលវែង មធ្យម និង ខ្លី	22 700
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1 000
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	45
៥០	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	21 300
៥១	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេស	40 000
៥២	កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ	17 000
៥៣	ការទូទាត់បំណុល	5 200
	សរុបផ្នែក ១	116 035
	ផ្នែក ៤ ខេត្តក្រុង	
១០	បៀវត្ស និង ប្រាក់បំណាច់	860
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	525
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	130
	សរុបផ្នែក ៤	1 515
	សរុបរួម ៧	117 550
	៨— ក្រសួងព័ត៌មាន	
	ផ្នែក ១- ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	790
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	2 000
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	45
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	15
៥០	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	3 000
	សរុបផ្នែក ១	5 850

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការរាយមុខ	ចំនួន ឥណទាន
	ផ្នែក ៤– ខេត្តក្រុង	
១០	បៀវត្ស និង ប្រាក់បំណាច់	750
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូចតាច	630
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	40
	សរុបផ្នែក ៤	1 420
	សរុបរួម ៨	7 270
	៩– ក្រសួងសាធារណការ និង ដឹកជញ្ជូន	
	ផ្នែក ១ – ក្រសួងកណ្តាល	
១០	បៀវត្ស និង ប្រាក់បំណាច់	1 315
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូចតាច	605
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	2 245
៥០	ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	65
៥១	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	10 000
	សរុបផ្នែក ១	111 730
	ផ្នែក ៤ – ខេត្តក្រុង	
១០	បៀវត្ស និង ប្រាក់បំណាច់	2 525
១១	ចំណាយដំណើរការ ការរដ្ឋបាល សំភារៈ និង ការជួសជុលតូចតាច	1 180
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	45
	សរុបផ្នែក ៤	3 750
	សរុបរួម ៩	115 480
	១០– ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	2 630
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូចតាច	4 030
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	900
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	230
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	15
៥១	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	48 500
	សរុបផ្នែក ១	56 305

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការរាយមុខ	ចំនួន ឥណទាន
	ផ្នែក ៤– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	3 630
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 600
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	960
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	80
	សរុបផ្នែក ៤	6 330
	សរុបរួម ១០	62 635
	១១– ក្រសួងយុត្តិធម៌	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	375
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 090
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
	សរុបផ្នែក ១	1 490
	ផ្នែក ២– តុលាការជាន់ខ្ពស់បំផុត	
១០	បៀវត្ស និង ប្រាក់បំណាច់	105
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	320
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ២	440
	ផ្នែក ៣– សាលាឧទ្ធរណ៍	
១០	បៀវត្ស និង ប្រាក់បំណាច់	55
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	100
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
	សរុបផ្នែក ២	160
	ផ្នែក ៤– ផ្នែកខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	400
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	520
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	40
	សរុបផ្នែក ៤	960
	សរុបរួម ១១	3 050

ការចាត់គ្រប់គ្រងឆ្នាំ ១៩៩៥

តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	១២— ក្រសួងអប់រំយុវជននិងកីឡា	
	ផ្នែក ១– អប់រំ	
១០	បៀវត្ស និង ប្រាក់បំណាច់	930
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	5 020
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	200
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	30
៥១	ការវិនិយោគដោយហិរញ្ញប្បទានធនធានផ្ទាល់	42 100
	សរុបផ្នែក ១	48 280
	ផ្នែក ២– ឧត្តមសិក្សា	
១០	បៀវត្ស និង ប្រាក់បំណាច់	1 405
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	420
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	525
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	20
	សរុបផ្នែក ២	2 370
	ផ្នែក ៣– យុវជននិងកីឡា	
១០	បៀវត្ស និង ប្រាក់បំណាច់	340
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	820
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	100
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	50
	សរុបផ្នែក ៣	1 310
	ផ្នែក ៤– [illegible]	
១០	បៀវត្ស និង ប្រាក់បំណាច់	62 250
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	2 320
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	320
	សរុបផ្នែក ៤	64 890
	សរុបរួម ១២	116 850
	១៣— ក្រសួងពាណិជ្ជកម្ម	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	500
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	990
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	30
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	20
	សរុបផ្នែក ១	1 540

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	ផ្នែក ៤– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	3 630
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 600
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	960
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	80
	សរុបផ្នែក ៤	6 330
	សរុបរួម ១០	62 635
	១១– ក្រសួងយុត្តិធម៌	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	375
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 090
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
	សរុបផ្នែក ១	1 490
	ផ្នែក ២– តុលាការជាន់ខ្ពស់បំផុត	
១០	បៀវត្ស និង ប្រាក់បំណាច់	105
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	320
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ២	440
	ផ្នែក ៣– សាលាឧទ្ធរណ៍	
១០	បៀវត្ស និង ប្រាក់បំណាច់	55
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	100
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
	សរុបផ្នែក ២	160
	ផ្នែក ៤– ផ្នែកខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	400
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	520
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	40
	សរុបផ្នែក ៤	960
	សរុបរួម ១១	3 050

ការចាត់គ្រប់គ្រងឆ្នាំ ១៩៩៥

តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	ផ្នែក ២– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	750
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	675
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	85
	សរុបផ្នែក ២	3 050
	សរុបរួម ៣	9 600
	១៤— ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	470
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	340
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	3 785
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
៥១	ការវិនិយោគដោយហិរញ្ញប្បទានធនធានផ្ទាល់	44 200
	សរុបផ្នែក ១	48 820
	ផ្នែក ២– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	975
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	405
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	1 070
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	30
	សរុបផ្នែក ២	2 480
	សរុបរួម ១៤	51 300
	១៥— ក្រសួងព័ត៌មាន	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	265
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	415
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុបផ្នែក ១	690
	ផ្នែក ២– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	675
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់	310
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ២	1 000
	សរុបរួម ១៥	1 690

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	១៦– ក្រសួងសុខាភិបាល	
	ផ្នែក ១– ក្រសួង	
១០	ប្រៀវត្ស និង ប្រាក់បំណាច់	2 490
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	15 550
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	180
៥១	ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់	8 700
	សរុបផ្នែក ១	26 920
	ផ្នែក ៩– ខេត្តនានា	
១០	ប្រៀវត្ស និង ប្រាក់បំណាច់	8 070
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	9 865
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ៩	17 950
	សរុបរួម ១៦	44 870
	១៧– ក្រសួងទេសចរណ៍	
	ផ្នែក ១– ក្រសួង	
១០	ប្រៀវត្ស និង ប្រាក់បំណាច់	205
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	750
៣០	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
៣១	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	85
	សរុបផ្នែក ១	1 050
	ផ្នែក ៩– ខេត្តនានា	
១០	ប្រៀវត្ស និង ប្រាក់បំណាច់	215
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	130
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
	សរុបផ្នែក ៩	350
	សរុបរួម ១៧	1 400
	១៨– ក្រសួងធម្មការ និង កិច្ចការសាសនា	
	ផ្នែក ១– ក្រសួង	
១០	ប្រៀវត្ស និង ប្រាក់បំណាច់	170
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	300
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុបផ្នែក ១	480

ការចាយគ្រប់គ្រងឆ្នាំ ១៩៩៥
តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខជំពូក	ការរាយមុខ	ចំនួនឥណទាន
	២១— ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	500
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	550
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	350
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	30
	សរុបផ្នែក ១	1 430
	ផ្នែក ៩– ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	950
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	830
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	28 600
	សរុបផ្នែក ៩	30 380
	សរុបរួម ២១	31 810
	២២— ក្រសួងបរិស្ថាន	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	320
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 025
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	5
	សរុបផ្នែក ១	1 350
	ផ្នែក ៩– ខេត្តនានា	
១២	បៀវត្ស និង ប្រាក់បំណាច់	185
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	440
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	25
	សរុបផ្នែក ៩	650
	សរុបរួម ២២	2 000
	២៣— ក្រសួងអភិវឌ្ឍន៍ជនបទ	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	1 275
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	1 700
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	95
៦១	ការវិនិយោគហិរញ្ញប្បទានពីធនធានផ្ទាល់	49 200
	សរុបរួម ២៣	52 270

ថវិកាគ្រប់គ្រងឆ្នាំ ១៩៩៥

តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការចាយមុខ	ចំនួន ឥណទាន
	ផ្នែក ៤- ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	315
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	175
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុបផ្នែក ៤	500
	សរុបរួម ១៨	980
	១៩— ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	
	ផ្នែក ១ ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	1 100
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	26 485
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	10
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
៣២	អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	60
	សរុបផ្នែក ១	27 670
	ផ្នែក ៤- ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	445
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	330
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ១	790
	សរុបរួម ១៩	28 460
	២០— ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	
	ផ្នែក ១- ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	1 235
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	800
៣០	អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	5
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	100
	សរុបផ្នែក ១	2 140
	ផ្នែក ៤- ខេត្តនានា	
១០	បៀវត្ស និង ប្រាក់បំណាច់	1 250
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	400
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	10
	សរុបផ្នែក ៤	1 660
	សរុបរួម ២០	3 800

ការងារគ្រប់គ្រងឆ្នាំ ១៩៩៥

តារាងបែងចែកចំណាយជាប្រចាំ និង ជាមូលធន

ឯកតាគិតជាលានរៀល

លេខ ជំពូក	ការរាយមុខ	ចំនួន ឥណទាន
	១— ក្រសួងកិច្ចការនារី	
	ផ្នែក ១– ក្រសួង	
១០	បៀវត្ស និង ប្រាក់បំណាច់	100
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	350
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	100
	សរុបផ្នែក ១	550
	ផ្នែក ៩– ខេត្តតាកែវ	
១០	បៀវត្ស និង ប្រាក់បំណាច់	100
១១	ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច	245
៣១	អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌	15
	សរុបផ្នែក ៩	360
	សរុបរួម ២៤	910
	៣— ចំណាយផ្សេងៗ និងពុំបានគ្រោងទុក	
		3800
	សរុបរួម ៩៩	3 800
	សរុបរួមចំណាយថវិកាទូទៅរបស់រដ្ឋ	1 058 600

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៤ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង :

១-លោក **ឆាយ គីម** បច្ចុប្បន្នប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ក្រសួងអប់រំ យុវជន និងកីឡា ជាទីប្រឹក្សា.ឧ **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២-លោក **ជៀប ថេងហួត** ជាទីប្រឹក្សា.ឧ **យូ ហុកគ្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង និង ប្រធានស្ថាប័នពាក់ព័ន្ធ លោក **ឆាយ គីម** និង លោក **ជៀប ថេងហួត** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ០៥ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

បានឃើញគុណបំណាច់ របស់សប្បុរសជនក្នុងការចូលរួមស្តារ និង កសាងប្រទេសជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ១ ជូនចំពោះក្រុមហ៊ុនអាជីវកម្ម និង សប្បុរសជនដែលបានបរិច្ចាគ ទ្រព្យសម្បត្តិចូលរួមស្តារ និង កសាងប្រទេសជាតិ ដូចមាននាមខាងក្រោម ÷

១-ក្រុមហ៊ុន LAN SONG CO.LTD បានឧបត្ថម្ភប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិក សំរាប់កសាងវិស័យអប់រំ

២-លោក LAI CHUN HUA អគ្គនាយកក្រុមហ៊ុន KINGWOOD INDUSTRY PTE..LTD បានឧបត្ថម្ភ ប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិកសំរាប់កសាងវិស័យកសិកម្ម

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

២. សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ០៩ សសរ
ស្ដីពីការកំណត់សិទ្ធិ និង ភារកិច្ចរបស់បណ្ដាអង្គភាពដែលបំពេញកិច្ចការប្រចាំនៅអាកាសយានដ្ឋានអន្តរជាតិ ពោធិចិនតុង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : ក្រសួងមហាផ្ទៃមានភារកិច្ច និង សិទ្ធិ :

ក. អង្គភាពនគរបាលអន្តោប្រវេសន៍ ដែលបំពេញការងារនៅអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង មានភារកិច្ច និង សិទ្ធិដូចតទៅ ÷

- ត្រួតពិនិត្យលិខិតឆ្លងដែន និង ទិដ្ឋាការចេញ នៅកន្លែងបែបបទចេញដំណើរដែលកំណត់អោយប្រើប្រាស់ នគរបាលចំនួន ០៦ នាក់ ក្នុងមួយថ្ងៃ ។
- ត្រួតពិនិត្យលិខិតឆ្លងដែន និងទិដ្ឋាការចូលនៅកន្លែងមកដល់ដែលកំណត់អោយប្រើប្រាស់ នគរបាលចំនួន ០៨ នាក់ ក្នុងមួយថ្ងៃ ។
- ចាត់តាំងភ្នាក់ងារប្រចាំការចំនួន ០៦ នាក់ក្នុងមួយថ្ងៃ នៅកន្លែងបែបបទចូល ដើម្បីដោះស្រាយរាល់បញ្ហាដែល ទាក់ទងដល់ភ្ញៀវទេសចរណ៍ ដែលពុំទាន់មានទិដ្ឋាការចូល ។
- ចាត់តាំងប្រធាន ឬ អនុប្រធានមួយរូបសំរាប់ត្រួតពិនិត្យការងារប្រចាំថ្ងៃ របស់នគរបាលអន្តោប្រវេសន៍ ។

កំលាំងនគរបាលអន្តោប្រវេសន៍ដែលបំរើការនៅតាមកន្លែង ដែលបានកំណត់ខាងលើនេះនៅក្នុងស្ថានីយ៍អាកាសយានដ្ឋានអន្តរជាតិ ពោធិចិនតុងទាំងអស់មានតែ ២២ នាក់ ប៉ុណ្ណោះ ។ កំលាំងដែលនៅសល់ ពីនេះ ត្រូវបញ្ជូនទៅកាន់សាមីក្រសួងវិញ ។

ខ-អង្គភាពនគរបាលច្រកទ្វារព្រំដែន ដែលបំពេញការងារនៅអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង មានភារកិច្ច និង សិទ្ធិដូចតទៅ ÷

កំលាំងនគរបាលច្រកទ្វារព្រំដែន គឺកំណត់ចំនួន ០៤ នាក់ ក្នុង ០១ ថ្ងៃ សំរាប់ប្រចាំការនៅក្នុងការិយាល័យរបស់ខ្លួន នៅតាមទីកន្លែងដែលបានកំណត់ក្នុងអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។ កំលាំងនេះមានភារកិច្ចសហប្រតិបត្តិ ការជាមួយកងកំលាំងរក្សាសន្តិសុខ អាកាសចរ នៅពេលណាដែលកងកំលាំងសន្តិសុខអាកាសចរមានតំរូវការ ។ កំលាំងដែលនៅសល់ពីនេះត្រូវបញ្ជូនទៅកាន់សាមីក្រសួងវិញ ។

ប្រការ ២ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ច និង សិទ្ធិ :

អង្គភាពគយ និង រដ្ឋាករដែលបំពេញកិច្ចការនៅអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង មានភារកិច្ច និង សិទ្ធិដូចតទៅ ÷

-ភ្នាក់ងារគយ និង រដ្ឋាករចំនួន ០១ នាក់ ក្នុង ១ ថ្ងៃ សហការជាមួយកងកំលាំងសន្តិសុខ អាកាសចរប្រចាំការត្រួត ពិនិត្យវ៉ាន់ទំនិញ សំភារៈ និងបញ្ញើនៅកន្លែងម៉ាស៊ីនត្រួតពិនិត្យពេលចេញដំណើរ ។ ដោយឡែកឧបករណ៍សំភារៈ គ្រឿងម៉ាស៊ីនត្រួតពិនិត្យ (X-RAY) ។ល។ គឺអាជ្ញាធរអាកាសយានដ្ឋានជាអ្នកគ្រប់គ្រង និង ថែរក្សា ។

-ភ្នាក់ងារគយ និង រដ្ឋាករចំនួន ០១ នាក់ ក្នុង ០១ ថ្ងៃ ប្រចាំការត្រួតពិនិត្យវ៉ាន់យួរដៃរបស់ភ្ញៀវក្រោយពេលភ្ញៀវបំពេញបែបបទរួចហើយ នៅកន្លែងម៉ាស៊ីនត្រួតពិនិត្យច្រកទ្វារខាងក្នុងពេលចេញដំណើរ ។

-ភ្នាក់ងារគយ និង រដ្ឋាករចំនួន ០៨ នាក់ ក្នុង ០១ ថ្ងៃ សំរាប់ត្រួតពិនិត្យវ៉ាន់ទំនិញ និងសំភារៈរបស់ភ្ញៀវពេលមក ដល់ ក្រោយពេលដែលភ្ញៀវបំពេញបែបបទទិដ្ឋាការរួចហើយ ។

-ភ្នាក់ងារគយ និង រដ្ឋាករចំនួន ០២ នាក់ ក្នុង ០១ ថ្ងៃ ប្រចាំការត្រួតពិនិត្យវ៉ាន់ទំនិញសំភារៈ និងបញ្ញើនៅកន្លែង ម៉ាស៊ីនត្រួតពិនិត្យពេលភ្ញៀវចូលមកដល់ ។

-ចាត់តាំងប្រធាន ឬ អនុប្រធាន ០១ នាក់ សំរាប់ត្រួតពិនិត្យការងារប្រចាំថ្ងៃរបស់ភ្នាក់ងារគយ និង រដ្ឋាករនៅក្នុង ស្ថានីយ ។

-ភ្នាក់ងារគយ និង រដ្ឋាករដែលបំពេញភារកិច្ចនៅតាមទីកន្លែងដែលបានកំណត់ខាងលើ នៅក្នុងស្ថានីយអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងទាំងអស់ក្នុង ០១ ថ្ងៃ មានតែ ១៤ នាក់ ប៉ុណ្ណោះ ។ ភ្នាក់ងារគយ និង រដ្ឋាករដែល នៅសល់ពីនេះត្រូវនៅប្រចាំការនៅការិយាល័យគយ និង ឃ្លាំងគយពោធិចិនតុង ។

ប្រការ ៣ : អង្គភាពសន្តិសុខអាកាសចរទទួលខុសត្រូវត្រួតពិនិត្យ ការពារសន្តិសុខ និង សណ្តាប់ធ្នាប់នៅគ្រប់ទីកន្លែងក្នុង បរិវេណ អាកាសយានដ្ឋានអន្តរជាតិ ពោធិចិនតុង ។

ប្រការ ៤ : ដើម្បីធានាដឹកនាំគ្រប់គ្រងអោយបានប្រសើរល្អ និង ឯកភាពគ្នាគឺចាំបាច់ត្រូវមានគណៈកម្មការមួយដែលមានឈ្មោះថា គណៈកម្មការគ្រប់គ្រង និង រក្សាសណ្តាប់ធ្នាប់សាធារណៈផ្ទៃក្នុងអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងដែលរួមមានសមាសភាពដូចតទៅ ÷

-នាយកអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ប្រធាន

-ប្រធានប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង សមាជិក

-ប្រធានស្នាក់ការគយច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង សមាជិក

គណៈកម្មការ គ្រប់គ្រង និង រក្សាសណ្តាប់ធ្នាប់សាធារណៈអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង មានសិទ្ធិ និង ភារកិច្ចដូចតទៅ ÷

-ទទួលខុសត្រូវលើកិច្ចការគ្រប់គ្រងរក្សាសណ្តាប់ធ្នាប់ និង សន្តិសុខក្នុងបរិវេណអាកាសយានដ្ឋានអន្តរជាតិពោធិ ចិនតុង នៅក្នុង និង ក្រៅម៉ោង ម៉ោងធ្វើការ ។

-មានសិទ្ធិប្រើប្រាស់កំលាំងសរុបដែលមានស្រាប់ នៅអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ដើម្បីសំរេចភារកិច្ច របស់ខ្លួនអោយបានល្អតាមការចង្អុលដឹកនាំរបស់រាជរដ្ឋាភិបាល ។

-មានរបបប្រជុំជាធម្មតា និង វិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ដើម្បីដកពិសោធន៍ និង ដាក់ចេញនូវវិធានការគ្រប់គ្រងរក្សាសណ្តាប់ធ្នាប់ និង សន្តិសុខក្នុងអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង បណ្តាស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ១០ សសរ
ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ផ្អែកតាមការងារចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូន ឯកឧត្តម **សុខ អាន** ឯកឧត្តម **ម៉េង សិរីចុឡា** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋ លេខាធិការស្តីទី នៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ចាប់ពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៥ រហូតដល់ថ្ងៃឯកឧត្តម កេវ៉ុត សុគន្ធ ត្រឡប់មកពី ព្យាបាល រោគនៅប្រទេសអូស្ត្រាលីវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **សុខ អាន** និង ឯកឧត្តម **ម៉ែន សំអុន** ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

II - ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ០០១ សហវ.ខ.សសរ

ស្តីពីការបង្កើតគណៈកម្មការរៀបចំអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រង មន្ត្រីរាជការគយរដ្ឋាករ តាមស្មារតីសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០០១សរ. សហវ.គរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤

-បានឃើញសារាចររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០០១ សរ.សហវ.គរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥

-បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយដើម្បីរៀបចំ អនុវត្តគោលការណ៍ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាករដែលមាន សមាសភាពដូចខាងក្រោមនេះ :

១-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការ ប្រធាន

២-ឯកឧត្តម **នាយ ផន** អនុរដ្ឋលេខាធិការ អនុប្រធាន

៣-ឯកឧត្តម **ឌា ម៉េងឈាង** អនុរដ្ឋលេខាធិការ អនុប្រធាន

៤-លោក **សា វ៉ាត់ ខាន់** អគ្គនាយកស្តីទី នាយកខុទ្ទកាល័យ សមាជិក

៥-លោក **ស ហួរ** នាយកទីចាត់ការគយនិងរដ្ឋាករ សមាជិក

៦-លោក **ប្រាក់ ឈៀង** ប្រធានមន្ទីរ សមាជិក

៧-លោក **មោក សុធារិន** ប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៨-លោក **អ៊ុយ សម្បត្តិ** នាយករងទី ១ ទីចាត់ការគយនិងរដ្ឋាករ លេខាធិការ

៩- លោក **ពេជ ចន្ទ** នាយកទីចាត់ការគយ និង រដ្ឋាករ សមាជិក

ប្រការ ២ : គណៈកម្មការមានភារកិច្ចដូចតទៅនេះ :

-ពិភាក្សាវាយតំលៃស្ថានភាពជាក់ស្តែង (Etat de lieux) ទាំងរចនាសម្ព័ន្ធ និង ស្ថានភាពមន្ត្រីរាជការគយនិង រដ្ឋាករ អោយបានច្បាស់លាស់ជាមុន ។

-កំណត់អាទិភាព និងវិធានការដែលត្រូវអនុវត្តបន្ទាន់មុនគេសំខាន់គឺ ចំណុចទី ១.ខ ស្តីពីការតែងតាំង និង ការផ្លាស់ប្តូរមន្ត្រីរាជការគយនិងរដ្ឋាករ និងការងារដែលត្រូវធ្វើជាបន្តបន្ទាប់ទៀត ដើម្បីធានាបានប្រសិទ្ធភាពនៃការ អនុវត្តសារាចរ លេខ ០០១ សរ.សហវ.គរ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ ។

-ប្តូកសរុបលទ្ធផលនៃការពិភាក្សាដាក់ជូន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច ។ ចំពោះលទ្ធផលនៃការរៀបចំអនុវត្តត្រង់ចំណុចទី ១.៤ គណៈកម្មការត្រូវធ្វើអោយចប់ជាស្ថាពរ និងត្រូវរាយ ការណ៍សុំសេចក្តីសំរេចពីឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៥ នេះ ។

ប្រការ ៣ : -អនុប្រធាននិងសមាជិកទាំងអស់នៃគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

-ក្នុងពេលអវត្តមានប្រធានគណៈកម្មការ, អនុប្រធានត្រូវទទួលបន្ទុកចាត់ចែងការងារជំនួសប្រធាន ។

-ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការមានសិទ្ធិអញ្ជើញ មន្ត្រីរាជការមានសមត្ថកិច្ចដទៃទៀតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចូលរួមប្រជុំពិភាក្សា ជាមួយគណៈកម្មការតាមជាក់ស្តែង ។

ប្រការ ៤ : ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរ ទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានបុគ្គលិក និងបណ្តាអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

***

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១២ ពណ.បលប្រក

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-យោងតាមប្រកាសលេខ ៦១៥ ពណ.ចត.ប្រក ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩១ របស់ក្រសួងពាណិជ្ជកម្ម

-យោងតាមការចាំបាច់ របស់ក្រសួងពាណិជ្ជកម្ម

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចបន្ថែមដល់ ការិយាល័យទាក់ទងបរទេស នៃនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ដូចតទៅ :

-សហការជាមួយផ្នែកនានា ដែលស្ថិតក្រោយឱវាទក្រសួង ដើម្បីស្រាវជ្រាវអំពីការស្នើសុំជំនួយពីបរទេស សំដៅបំពេញសេចក្តីត្រូវការចាំបាច់ទាំងខាងស្មារតី និងសំភារៈ សំរាប់អភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ។

-រៀបចំគំរោងផែនការ ស្នើសុំជំនួយបរទេស គំរោងការបែងចែកជំនួយដល់បណ្តាផ្នែក ។

-តាមដាន និង បូកសរុបតំលៃសំភារៈ និង ទឹកប្រាក់ ដែលជាជំនួយបរទេស ។ ពិនិត្យវាយតំលៃអំពីប្រសិទ្ធភាពនៃ ការប្រើប្រាស់របស់បណ្តាផ្នែកដែលត្រូវបានទទួលជំនួយបរទេស ។

ប្រការ ២ : ប្រធានបន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និង ការិយាល័យទាក់ទងបរទេស ត្រូវអនុវត្តតាមប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

***

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤៦ ឧក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ឈន សារ៉ាណេ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ៣០២៧៩៣ ក.រា ចុះថ្ងៃទី ១០-០១-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩ ផ្លូវលេខ ៣៦១ ក្រុមទី ៣ ភូមិ កណ្តាល ឃុំ ច្បារអំពៅទី ២ ស្រុក មានជ័យ រាជធានីភ្នំពេញ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ អង្ករ យីហោ " មាន-ហួរ " កំលាំង ២២ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ឈន សារ៉ាណេ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុង ប្លង់ ដោយធានានូវអង្ករមានគុណភាពខ្ពស់ និង ភាពសុចរិតក្នុងអាជីវកម្មរបស់ខ្លួន ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ុង ប្រាំង

***

ប្រកាសលេខ ៥៤ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវដែលមាន អ្នកស្រី ជា ហ៊ាង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ១២៥២៤២ ព.ស . ចុះថ្ងៃទី ០៤-៣-៩៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិ អូរតាប៉ោង ឃុំ អូរតាប៉ោង ស្រុក បាកាន ខេត្ត ពោធិសាត់ បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៦០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី ជា ហ៊ាង ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុង ប្លង់ដោយធានានូវអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ញូ សុធីរៈ

***

ប្រកាសលេខ ៥៥ ជក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ហុង វេងស៊ា ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាប័ណ្ណលេខ ១២៨៤៧៦ ព.ស ចុះថ្ងៃទី ១៣-៥-៩២ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៥ ភូមិ សំរោង ឃុំ កញ្ជរ ស្រុក កណ្តៀង ខេត្ត ពោធិសាត់ បើកដំណើរការឧស្សាហកម្មផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ញូ សុធីរៈ

***

៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១៦ ប្រក.កសក.ចក
ស្តីពីការតែងតាំងគ្រូបង្រៀន ប្រចាំសាលា មធ្យមសិក្សាកសិកម្ម ព្រែកលៀប ឆ្នាំសិក្សា ១៩៩៤-១៩៩៥

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីប្រាក់កំរៃបន្ថែមគរុកោសល្យលើបៀវត្ស ជូនបុគ្គលិកសិក្សាគ្រប់ជាន់ថ្នាក់
- តាមសំណើលេខ ១២ សពាល.ចត ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៥ របស់សាលាមធ្យមសិក្សាកសិកម្ម ព្រែកលៀប

សំរេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការរបស់សាលាមធ្យមសិក្សាកសិកម្មព្រែកលៀប ចំនួន ១៣៥ នាក់ និង មន្ត្រីរាជការជាគ្រូបង្រៀនខ័ណ្ឌត្រៀមសំរាប់សាលាកសិកម្មខេត្តកំពង់ចាម ចំនួន ២៥ នាក់ អោយទទួលបន្ទុកជាគ្រូបង្រៀនសំរាប់ឆ្នាំ ១៩៩៥ ដូចមានរាយឈ្មោះខាងក្រោម :

I- គ្រូប្រចាំសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប :

ក-កំរិត ឧត្តម ចំនួន ៥២ នាក់

១-លោក ចាយ ស៊ុនហ៊ាង	៧-លោក ប៉ែន បុល្លីកា
២-លោក ទូច សៀម	៨-លោក ពាំង ផល្គុណ
៣-លោក ទូច សារ៉ាត	៩-កញ្ញា រាត់ មល្លិកា
៤-លោក ឡុប គុណបុត្រ	១០-លោក ចាន់ ឫទ្ធី
៥-លោក លាង អ្នខេង	១១-លោក ទី ឌីណា
៦-លោក ព្រំ វឌ្ឍា	១២-លោក ជ័យ បន្ថា
១៣- លោក ចាន់ វឌ្ឍតា	៣៣-លោក ស៊ុន ហេង
១៤-លោកស្រី ទិត មរកត	៣៤-លោក សួខន សារុទ្ធ
១៥-លោក ស៊ិន ហេង	៣៥-លោក តោ វ៉ាជា
១៦-កញ្ញា ហេង រត្នមាណវី	៣៦-លោក ស្រេង ធុនរី
១៧-លោក ចាង ហួត	៣៧-លោក ពេជ សូភិន
១៨-លោក ជាប លីឆាយ	៣៨-លោក ទុយ សមរាំ
១៩-លោក ទិត្យ សារ៉ុន	៣៩-លោក ឆេង ទូច
២០-លោក ឃឹម សៀម	៤០-លោក និល ជិនរី
២១-លោក ភួក យ៉េង	៤១-លោក រី សំអែល
២២-លោក ឌី ផល្លា	៤២-លោក វ៉ន កុយ
២៣-លោក ព្រំ ធុលា	៤៣-លោក អ៊ុក គុណកា
២៤-លោក ប៊ុច ស៊ីថន	៤៤-លោក ស៊ូ សុន្ទរ៉ា
២៥-លោក ម៉េង សុខុន	៤៥-លោក នួន អុល

២៦_លោក ហៀង សួរ

២៧_លោក ហាវ ផលសម្បត្តិ

២៨_លោក ឡេង ប៉ូ

២៩_កញ្ញា អ្នក សុគន្ធា

៣០_លោក ព្រំ ថា

៣១_លោក ទី តៀង

៣២_លោក ជ្រឹង ស៊ីង

៤៦_លោក ប៉េង ឃៀង

៤៧_លោក សាន ស្រ៊ុន

៤៨_កញ្ញា ហុង គឹមអ៊ាង

៤៩_កញ្ញា កៅ ប៉ី

៥០_លោក ងួន ណៃត

៥១_លោក ថន សុធី

៥២_លោក អ៊ុក សៀកផេង

ខ.ភិរក មធ្យម ចំនួន ៥៩ នាក់

១_លោក ភីវ សុវណ្ណា

២_លោកស្រី ពៅ កាចៀន

៣_លោក ស៊ិន សាប៉ន

៤_លោក សោម សាខា

៥_លោក នង សារី

៦_កញ្ញា អាន មួយឆ៊ិច

៧_លោក ព្រំ ហាក់

៨_លោក ជា សារិន

៩_លោក ឈុប ស៊ីផុន

១០_កញ្ញា អ៊ិត ណារី

១១_លោក ចាយ រ៉េតវណ្ណៈ

១២_កញ្ញា ឈុំ ស៊ីវ៉ុម

១៣_លោក សូ សុវឌ្ឍារ

១៤_លោក សេង ហៃ

១៥_លោកស្រី ចាន់ផល្លា

១៦_លោក ចាន់ សុផល

១៧_លោកស្រី ឃាម គីមនី

២១_លោក វ៉ា វ៉េងហេង

២២_កញ្ញា ខៃ ចារុវណ្ណ

២៣_កញ្ញា ផេន សុជាតិ

២៤_លោក លី គីមសែ

២៥_លោក អ៊ិន សុខហេង

២៦_លោក ខៀវ នាង

២៧_លោកស្រី អ៊ុក ឈីវឡាយ

២៨_លោក សួរ្យ សេដ្ឋា

២៩_លោក ហេង លីមហួត

៣០_លោក ទេព ចាន់ដារ៉ា

៣១_លោក អ៊ុក ប៉ែនធុល

៣២_លោក ឆែម ថា

៣៣_លោក ទូច ហេងវណ្ណ

៣៤_លោក ខាត់ សុខន

៣៥_លោក ចឹក សូវុធ

៣៦_ លោក គង់ វ៉ុន

៣៧_លោក ផុន ចាន់សុផល

១៨_កញ្ញា សេង ស្រី ៣៨_លោក អៀម ទ្រី

១៩_លោកស្រី ឡេង សុធារី ៣៩_លោក ឡុង អង្គារវង្ស

២០_កញ្ញា ជីវ ចាន់សុភាព ៤០_លោក ឥង សុវណ្ណារ៉ា

ខ.ភិក្ខុ មធ្យម ចំនួន ៥ នាក់

១_លោក នុត សុជាតិ

២_លោក ឡី គីមហេង

៣_លោក ទៀវ វុត្ថា

៤_លោក កែវ សារ៉ាន់

៥_លោក គួរ សារ៉េត

មាត្រា ២ : គ្រូបង្រៀនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលប្រាក់កំរៃតុកោសល្យ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ ។

មាត្រា ៣ : ប្រកាសមុនៗ ដែលពាក់ព័ន្ធនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : ប្រធានមន្ទីរ , ប្រធាននាយកដ្ឋានចាត់តាំង_បុគ្គលិក , ប្រធាននាយកដ្ឋានផែនការ ស្ថិតិ , ប្រធាននាយកដ្ឋាន គណនេយ្យ_ហិរញ្ញវត្ថុ , នាយកសាលាមធ្យមសិក្សាកសិកម្មព្រែកលៀប និង សាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ជ.រដ្ឋមន្ត្រី

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ម៉ែន សំអឿន

***

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០២០ ប្រក.កសក.ចក
ស្តីពីការបង្កើតគណៈកម្មការអធិការកិច្ចលើចំនួនក្របខ័ណ្ឌរបស់ក្រសួង

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ចនិង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញសេចក្តីជូនដំណឹងលេខ ១៩៤៤ សជណ.សរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ទីស្តីការគណៈ រដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការអធិការកិច្ចមួយក្រុមសំរាប់ត្រួតពិនិត្យលើចំនួនក្របខ័ណ្ឌរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោម :

១_លោក **ស៊ូ វៃណា**	ប្រធានគណៈកម្មាធិការត្រួតពិនិត្យក្រសួង	ប្រធាន
២_លោក **ស៊ឹម ហាខ្យ**	អនុប្រធាននាយកដ្ឋានចាត់តាំងនិងកម្មាភិបាល	អនុប្រធាន
៣_លោក **សុក ហ៊ាខ**	អនុប្រធានការិ.កម្មាភិបាល_បណ្តុះបណ្តាល	សមាជិក
៤_លោក **ប្រាក់ សំអុន**	អនុប្រធានការិ.បៀវត្ស_ពលកម្ម	សមាជិក
៥_លោក **លឹម ជីគង់**	មន្ត្រីរាជការគណៈកម្មាធិការត្រួតពិនិត្យក្រសួង	សមាជិក
៦_លោក **ណាំ លីមា**	មន្ត្រីរាជការគណៈកម្មាធិការត្រួតពិនិត្យក្រសួង	សមាជិក
៧_លោក **ឡាយ ទេពឈាន**	មន្ត្រីរាជការន.ចាត់តាំងនិងកម្មាភិបាល_រាយការណ៍	សមាជិក

មាត្រា ២ : គណៈកម្មការនេះ មានភារកិច្ចធ្វើអធិការកិច្ចទៅលើចំនួនក្របខ័ណ្ឌរបស់ក្រសួងទាំងមូលអោយបានច្បាស់លាស់ រួចរាយការណ៍ជូនក្រសួង ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង កម្មាភិបាល ប្រធាននាយកដ្ឋានផែនការស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងសាមីជនត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

***

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០២២ ប្រក.កសក.ចក
ស្តីពីការអនុញ្ញាអោយបើកកសិដ្ឋាន
ចិញ្ចឹមពូជមាន់សាច់

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណា ចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ចនិង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម .
- តាមសំណើរបស់លោក **ឡា សុភ័ក្ត** ចុះថ្ងៃទី ២២-១២-៩៤
- តាមសំណើរបស់លោក ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឆ្សា សុភិក្ត** ទីលំនៅផ្ទះលេខ ៣ សេរី ០ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខ័ណ្ឌ ចំការមន បើកកសិដ្ឋានរយៈពេលមួយឆ្នាំ ដើម្បីចិញ្ចឹមពូជមាន់សាច់មួយកន្លែងនៅក្នុងភូមិព្រៃធំ ឃុំ ក្បាលកោះ ស្រុក គៀនស្វាយ ខេត្ត កណ្តាល ដែលមានឈ្មោះថា សហហ្វាម ។

ប្រការ ២ : កសិដ្ឋានចិញ្ចឹមពូជមាន់សាច់កំណត់ដោយប្រការមួយខាងលើ ត្រូវបានគ្រប់គ្រងដោយវិស្វករផលិតកម្ម និង បសុពេទ្យាបាល ម្នាក់ដែលមានអតីតភាពការងារមិនតិចជាង ៣ ឆ្នាំ ហើយដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទទទួលស្គាល់ ។

ប្រការ ៣ : សាមីកសិដ្ឋាន ដែលបានទទួលការអនុញ្ញាត ត្រូវប្រតិបត្តិតាមលក្ខខ័ណ្ឌខាងក្រោម ÷

ក- គោរពច្បាប់អាជីវកម្ម និង ការចិញ្ចឹមសត្វដែលរដ្ឋបានកំណត់ ។

ខ- គោរពបទបញ្ញត្តិ ស្តីពីវិធានការការពារ និងវិធានការអនាម័យបសុពេទ្យាបាលអោយបានត្រឹមត្រូវ ។

គ- ត្រូវមានបទបញ្ញត្តិ ស្តីពីវិធីសាស្ត្រនៃការគ្រប់គ្រងច្បាស់លាស់ ដើម្បីចៀសវាងការបង្កជំងឺផ្សេង ៗ

ឃ- បង្កលក្ខណៈងាយស្រួលដល់ការចុះត្រួតពិនិត្យណែនាំការងារជំនាញផ្សេង ៗ ដែលរៀបចំ និងចាត់តាំងឡើងដោយនាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល ។

ង- អនុញ្ញាតអោយក្រុមសិក្សាស្រាវជ្រាវចុះស្រង់ពត៌មានផ្សេង ៗ ដែលពាក់ព័ន្ធ ។

ប្រការ ៤ : - កសិដ្ឋានចិញ្ចឹមពូជមាន់សាច់ មានសិទ្ធិដូចតទៅ:

ក- ធ្វើការទំនាក់ទំនងជាមួយកសិដ្ឋានចិញ្ចឹមសត្វឯទៀតនៅក្នុងប្រទេស និង នៅក្រៅប្រទេស ដើម្បីដោះដូរបច្ចេកទេសវិជ្ជាទំនើប ៗ និង បទពិសោធន៍សំខាន់ ៗ ។

ខ- នាំចូលពូជមាន់សាច់ពីបរទេសសំរាប់ការចិញ្ចឹម និង សាកល្បងផ្ទាល់ខ្លួនតាមចំនួន និង ប្រភេទដែលបានកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

គ- នាំចូលថ្នាំ ការពារ ព្យាបាលសត្វ ឧបករណ៍ បរិក្ខាសំរាប់ចិញ្ចឹម គ្រឿងម៉ាស៊ីនសំរាប់ផលិតចំណីសត្វ និង មធ្យោបាយផ្សេង ៗ ទៀតដែលពាក់ព័ន្ធ ។

ប្រការ ៥ : វិស្វករផលិតកម្ម និង បសុពេទ្យាបាល ទទួលបន្ទុកគ្រប់គ្រងកសិដ្ឋាន ត្រូវទទួលខុសត្រូវចំពោះច្បាប់រដ្ឋ ក្នុងករណីដែលផលិតផលរបស់កសិដ្ឋាន បានបង្កអោយមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ដោយ

សារធាតុណាភាពសាច់មិនល្អ ឬ ដោយសារនៅមានជីវជាតិពុលផ្សេងៗ ក្នុងសាច់ បន្ទាប់ពីសត្វ នៅបានទទួលការព្យាបាលជំងឺនានា ហើយមិនទាន់ដល់កំណត់អនុញ្ញាតអោយប្រើប្រាស់ ។

ប្រការ ៦ : ក្នុងដំណើរការផលិត កសិដ្ឋានត្រូវឆ្លងកាត់នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ។

ប្រការ ៧ : ប្រការនេះមានតំលៃអនុវត្តក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៨ : ប្រកាសអនុញ្ញាតអោយបើកកសិដ្ឋានដូចមានចែងក្នុងប្រការ ២ ត្រូវទុកជានិរាករណ៍ ដោយប្រកាសរបស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ ក្នុងករណីដែលបានពិនិត្យឃើញថា សាមីកសិដ្ឋាន បានគោរពតាមខ្លឹមសារនៃពាក្យស្នើសុំរបស់ខ្លួន ឬ ប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ ។

ប្រការ ៩ : លោក ប្រធានមន្ទីរ នៃ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ លោកប្រធាន នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល លោកប្រធានមន្ទីរកសិកម្ម និង លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត កណ្ដាល ត្រូវអនុវត្តប្រការនេះតាមភារកិច្ចរៀងៗខ្លួន ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អនុរដ្ឋលេខាធិការ

ម៉ៃ សំអឿន

***

៥- ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០១៣/៩៥ ពម.ប្រក

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១-១១-៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងសេចក្ដីជូនដំណឹង លេខ ១.២២៤-៩៤ ព.ម ចុះថ្ងៃទី ១៤-១១-៩៤ ស្ដីពីការបោះពុម្ពផ្សាយរបស់ក្រសួងពាណិជ្ជកម្ម

-យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ " សន្តិភាព " របស់អ្នកស្រី ជួង សម្ផស្ស ចុះថ្ងៃទី ០២-១២-៩៤

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី ជួង សម្ផស្ស សញ្ជាតិ ខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៨ អឺ ២ ផ្លូវលេខ ១០៨ សង្កាត់ វត្តភ្នំ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្ម រោងពុម្ពដែលមានឈ្មោះ " សន្តិភាព " សំរាប់បោះពុម្ពផ្សាយគ្រប់មុខ ស្ថិតនៅផ្ទះលេខ ២.៣៩៨ អា ផ្លូវលេខ ៤៥ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមខសន្យាសមស្របទៅនឹងទំនៀមទំលាប់ប្រពៃណីល្អ និង សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ត្រូវគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋាន គ្រប់គ្រងការបោះពុម្ពផ្សាយ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង ប្រធានមន្ទីរព័ត៌មាន រាជធានីភ្នំពេញ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

៦. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៦ ប្រក.មស.បល

ស្តីពីការលប់ឈ្មោះមន្ត្រីរាជការ

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល ។

-ពិនិត្យសំណើសុំលាឈប់ពីការងាររបស់សាមីខ្លួន ។

សំរេច

ប្រការ ១ : ត្រូវបានលុបឈ្មោះអ្នកស្រី **សុខ មន្ថា** ចេញពីបញ្ជីក្របខ័ណ្ឌបៀវត្ស របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ ដោយសាមីខ្លួន សុំលាឈប់ពីការងារ ។

ប្រការ ២ : លោកនាយខុទ្ទកាល័យ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ។

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

***

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៥០ ប្រក.មស.បល

ស្តីពីការលប់ឈ្មោះមន្ត្រីរាជការ

រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០.៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល ។

-បានឃើញសេចក្តីប្រកាសរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាលេខ ១៦២រស៩៤ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

សំរេច

ប្រការ ១ ៖ ត្រូវបានលុបឈ្មោះលោកជំទាវ **គង់ សុផាត** ចេញពីបញ្ជីបៀវត្សរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចាប់ពីថ្ងៃទី ០១-០១-៩៥ នេះតទៅ ។

ប្រការ ២ ៖ លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋាននីតិកម្ម និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ។

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា និង ត្រា

ប្រាក់ សុខ

***

៧- ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥/៩៥ គធស

ស្តីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ១៧ ក្រ ចុះថ្ងៃទី ៨ កុម្ភៈ ឆ្នាំ ១៩៩២

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងធម្មការ និង សាសនា

-តាមសំណើរបស់ ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានសាសនា ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥

-បានឃើញការចាំបាច់ របស់ក្រសួង ។

សំរេច

ប្រការ ១ : តែងតាំង

-លោក **សុម រ៉េសម៉ាង** អនុប្រធាននាយកដ្ឋានសាសនាទទួលបន្ទុកសាសនាឥស្លាម

-លោក **សុម សូឡេស** ជានាយការិយាល័យស្ថិតិនាយកដ្ឋានសាសនា

ប្រការ ២ : ខុទ្ទកាល័យ, នាយកដ្ឋានសាសនា នាយកដ្ឋានរដ្ឋបាល+ហិរញ្ញកិច្ច និងអស់លោកដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលភារកិច្ចអនុវត្ត សេចក្តីប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះ មានអានុភាពតាំងពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋលេខាធិការដ្ឋាន

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ៉ុត

***

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៦៧២ រៀល